

## សេចក្តីប្រកាសព័ត៌មាន

# ភាគីបានចុះហត្ថលេខានៅលើអនុស្សរណៈយោគយល់គ្នា ដើម្បីបន្តប្រតិបត្តិការ គម្រោងរោងចក្រកាន់តែប្រសើរនៅកម្ពុជា នៃអង្គការអន្តរជាតិខាងការងារ

ថ្ងៃទី ០៨ ខែវិច្ឆិកា ឆ្នាំ២០១៦

ភ្នំពេញ, ប្រទេសកម្ពុជា៖ រាជរដ្ឋាភិបាលកម្ពុជា (ក្រសួងពាណិជ្ជកម្ម និងក្រសួងការងារ) សមាគមរោងចក្រកាត់ដេរនៅកម្ពុជា និងគម្រោងរោងចក្រកាន់តែប្រសើរនៅកម្ពុជា នៃអង្គការអន្តរជាតិខាងការងារ នៅថ្ងៃនេះ បានចុះហត្ថលេខានៅលើអនុស្សារណៈនៃការយោគយល់គ្នា (MoU) ដើម្បីកែលម្អលក្ខខណ្ឌការងារ និងបង្កើនការប្រកួតប្រជែងនៅក្នុងឧស្សាហកម្មកាត់ដេររបស់កម្ពុជា។

អនុស្សរណៈនេះ នឹងឆ្លុះបញ្ចាំងពីភាពជាដៃគូបន្ត សម្រាប់រយៈពេលបីឆ្នាំខាងមុខទៀត ដែលគ្របដណ្តប់រយៈពេលចាប់ពីខែមករាឆ្នាំ២០១៧ ដល់ខែធ្នូឆ្នាំ២០១៩ ដែលដៃគូបានប្តេជ្ញាចិត្ត ដើម្បីបង្កើនការសហការគ្នា និងធ្វើការរួមគ្នាក្នុងការកែលម្អលក្ខខណ្ឌការងារ និងបង្កើនការប្រកួតប្រជែងនៃវិស័យកាត់ដេរ ដើម្បីបង្កើននិរន្តរភាពស្ថាប័ននៃកម្មវិធីនេះ។ ស្ថាប័នដៃគូនៅកម្ពុជា បានព្រមព្រៀងគ្នាក្នុងការចូលរួមចំណែកប្រមាណ២៥ភាគរយ ទៅកាន់ហិរញ្ញវត្ថុរបស់ BFC ក្នុងរយៈពេលបីឆ្នាំខាងមុខ ខណៈពេលដែលអ្នកទិញសម្លៀកបំពាក់អន្តរជាតិពីប្រទេសកម្ពុជាដែលប្រើប្រាស់របាយការណ៍វាយតម្លៃលក្ខខណ្ឌការងារ ពីគម្រោង ILO-BFC និងរោងចក្រដែលចូលរួមនៅក្នុងវគ្គបណ្តុះបណ្តាលរបស់គម្រោង BFC នឹងរួមចំណែកទៅនឹងប្រតិបត្តិការរបស់គម្រោង តាមរយៈថ្លៃសេវាបណ្តុះបណ្តាល ដែលចូលរួម។

កម្មវិធី BFC នឹងបន្តធ្វើការវាយតម្លៃស្តីពីលក្ខខណ្ឌការងារ នៅក្នុងរោងចក្រកាត់ដេរ ទៅតាមច្បាប់ស្តីពីការងាររបស់ប្រទេសកម្ពុជា និងបទដ្ឋានការងារស្នូលដែលទទួលស្គាល់ជាអន្តរជាតិ និងរាយការណ៍អំពីការរកឃើញរបស់ខ្លួនជាសាធារណៈ ដោយបកស្រាយយ៉ាងលម្អិត អំពីការអនុលោម និងមិនអនុលោមទៅតាមច្បាប់របស់រោងចក្រ។ សេវាកម្មប្រឹក្សាយោបល់ និងវគ្គបណ្តុះបណ្តាល ស្តីពីភាពធ្វើឱ្យប្រសើរឡើង និងបង្កើនផលិតភាពនៅកន្លែងការងារ នឹងបន្តប្រតិបត្តិការជាទៀងទាត់ ជាមួយនឹងការយកកម្រៃសេវា សម្រាប់សេវាកម្មទាំងនេះ។ BFC ក៏នឹងធ្វើការជាមួយក្រសួងការងារ ស្តីពីការអនុវត្តយុទ្ធសាស្ត្រ និងផែនការសកម្មភាពរួមគ្នា ជាមួយនឹងរដ្ឋាភិបាល ជុំវិញការបង្កើនសមត្ថភាពសម្រាប់ការធ្វើអធិការកិច្ចនៅកន្លែងធ្វើការ និងភាពជាម្ចាស់ការរបស់រដ្ឋាភិបាលដើម្បីលើកកម្ពស់ការអនុលោមតាមច្បាប់ការងារ និងការគាំទ្រ ក្នុងការដោះស្រាយបញ្ហាក្នុងវិស័យកាត់ដេរនិង/ឬវិស័យផ្សេងទៀត ទៅតាមភាពសមរម្យ។

នៅក្នុងសន្និសីទនាពេលថ្មីៗនេះ ដែលធ្វើឡើងជាមួយដៃគូរបស់ BFC ដើម្បីបង្ហាញពីការងាររបស់គម្រោងដែលបាន ប្រតិបត្តិការរបស់ពេល១៥ឆ្នាំកន្លងមកនេះ និងភាពជាដៃគូក្នុងវិស័យកាត់ដេរ, អ្នកបង្កើតគោលនយោបាយ មានមតិរួមគ្នាថា ការពង្រីកភាពជាដៃគូ នឹងបន្តជួយកែលម្អលក្ខខណ្ឌការងារ ស្របពេលដែលពង្រឹងការប្រកួតប្រជែងនៃឧស្សាហកម្ម កាត់ដេរនេះ ។ រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ **ឯកឧត្តម អ៊ិត សំហេង** បានមានប្រសាសន៍ថា "គម្រោង BFC បានដើរតួនាទីយ៉ាងសំខាន់ក្នុងការអភិវឌ្ឍឧស្សាហកម្មនេះ និងធ្វើឱ្យប្រសើរឡើងនូវលក្ខខណ្ឌការងារ" ។ លោកបាន បន្ថែមទៀតថា ក្រោមអនុស្សរណៈនៃការយោគយល់គ្នានេះ BFC និងក្រសួងការងារ នឹងបង្កើនការសហការលើការ ត្រួតពិនិត្យនៅកន្លែងការងារ និងពង្រឹងការអនុវត្តន៍ច្បាប់ការងារ ។ ជាមួយគ្នានេះដែរ រដ្ឋមន្ត្រី ក្រសួងពាណិជ្ជកម្ម **ឯកឧត្តម ប៉ាន សូរស័ក្តិ** បានកោតសរសើរ BFC ចំពោះការខិតខំរួមចំណែករបស់ខ្លួន ដើម្បីការពារសិទ្ធិកម្មករ និងអភិវឌ្ឍ ឧស្សាហកម្មនេះ ។ **ឯកឧត្តម** បានមានប្រសាសន៍ថា "អនុស្សរណៈយោគយល់គ្នាថ្មីនេះ នឹងបន្តទ្រទ្រង់ផ្នែកហិរញ្ញវត្ថុ និងកិច្ចសហការកាន់តែប្រសើរ រួមទាំងការផ្ទេរចំណេះដឹងផ្នែកអធិការកិច្ចការងារដល់មន្ត្រីនៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ដើម្បីឱ្យស្របទៅនឹងការវិវត្តន៍នៃស្ថានការណ៍បច្ចុប្បន្ន និងទៅអនាគត" ។

**លោក DAVD Lamotte** នាយករងអង្គការអន្តរជាតិខាងការងារ បានមានប្រសាសន៍ថា "វិស័យកាត់ដេររបស់ប្រទេស កម្ពុជា មាន សារៈសំខាន់សម្រាប់កំណើនសេដ្ឋកិច្ចរបស់ប្រទេសនេះ និងសម្រាប់ធ្វើឱ្យប្រសើរឡើងនូវជីវភាពរបស់ ប្រជាជនកម្ពុជា ។ ការប្តេជ្ញាចិត្តជាថ្មីពីរាជរដ្ឋាភិបាល និងសមាគមរោងចក្រកាត់ដេរ ដើម្បីធ្វើការជាមួយ BFC ក្នុងការកែលម្អលក្ខខណ្ឌការងារ និងការប្រកួតប្រជែងនៅក្នុងវិស័យនេះ មានសារៈសំខាន់ជាខ្លាំង ក្នុងការធានា ថា វិស័យនេះទទួលបានសក្តានុពលពេញលេញរបស់ខ្លួន, ផ្តល់ការងារល្អប្រសើរជាងមុន ដែលមានប្រាក់ចំណូលកាន់ តែប្រសើរ និងបង្កើនការអភិវឌ្ឍនៅក្នុងប្រទេសនេះ" ។

**លោកវ៉ាន់ ស៊ូអៀង** ប្រធានសមាគមរោងចក្រកាត់ដេរនៅកម្ពុជា បានទទួលស្គាល់ថា BFC គឺជា ផ្នែកមួយដ៏សំខាន់នៃគោលនយោបាយរបស់រាជរដ្ឋាភិបាល ដែលបានជួយបង្កើនការនាំចេញ ។ លោកក៏បានអំពាវនាវ ដល់អ្នកបញ្ជាទិញ ដើម្បីប្តេជ្ញាទៅកាន់គម្រោងនេះ ហើយបន្តទិញទំនិញពីប្រទេសកម្ពុជា ជាមួយនឹងតម្លៃសមរម្យ ។

អនុស្សរណៈយោគយល់គ្នានេះ ត្រូវបានបន្តសារជាថ្មីជាលើកទី៥ ចាប់តាំងពីគម្រោង BFC នៃអង្គការអន្តរជាតិខាងការងារ ចាប់ផ្តើមប្រតិបត្តិការក្នុងឆ្នាំ២០០១ ។

*គម្រោងរោងចក្រកាន់តែប្រសើរនៅកម្ពុជា (BFC) គឺជាផ្នែកមួយនៃកម្មវិធីការងារប្រសើរជាងមុន ដែលជាការសហការ រវាងអង្គការអន្តរជាតិខាងការងារ និងសាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ ដែលកំពុងប្រតិបត្តិការនៅទូទាំងទ្វីបទាំងបី*

*ដើម្បីធ្វើការផ្លាស់ប្តូរនៅតាមខ្សែសង្វាក់ផ្គត់ផ្គង់ជាសកល នៅក្នុងវិស័យឧស្សាហកម្មកាត់ដេរ, ការងារ BFC នឹងក្លាយជាផ្នែកមួយទៅនឹងការចុះហត្ថលេខានេះ ដែលស្របទៅនឹងកម្មវិធីការងារសមរម្យនៅប្រទេសកម្ពុជា ។*

**សម្រាប់ព័តមានបន្ថែម សូមទាក់ទង៖**

លោកស្រី អិស្តេរ៍ ហើមិនស៍

ប្រធានគម្រោង ILO-BFC

អ៊ីម៉ែល៖ germans@ilo.org